Daiichi Life

# គម្រោង SECURECare និង SECURECare Plus

1 អត្ថប្រយោជន៍ការពាររហូតដល់ **700%**

2 **5** អត្ថប្រយោជន៍សរុបធំៗចំនួន៥ ក្នុងកញ្ចប់តែមួយ

3 ការបង់បុព្វលាភមានភាព **បត់បែន**



**ដាយ អ៊ិឈិ ឡាយហ្វ៍**

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតរបស់ប្រទេសជប៉ុន
ជាមួយប្រតិបត្តិការជាង១២៣ឆ្នាំ

## គម្រោង SECURECare និង SECURECare Plus

ការពារ និងផ្តល់ភាពស្ងប់ចិត្តផ្នែកហិរញ្ញវត្ថុជូនលោកអ្នក និងអ្នកជាទីស្រឡាញ់

**កម្មវត្ថុនៃការធានារ៉ាប់រងរបស់គម្រោង SECURECare និង SECURECare Plus** គឺធានាទៅលើអាយុជីវិតរបស់អ្នកត្រូវបានធានា ពីមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ពិការភាពដោយផ្នែកដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ សម្រាកនៅមន្ទីរពេទ្យបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ជម្ងឺឆ្លងដែលបានកំណត់ និងជាមួយនិងអត្ថប្រយោជន៍ដល់ថ្ងៃផុតកាលកំណត់ផងដែរ។

**វិសាលភាពនៃការធានារ៉ាប់រង**របស់គម្រោងនេះគឺធានាអាយុជីវិតអ្នកត្រូវបានធានារ៉ាប់រងទៅលើហានិភ័យមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ដែលបណ្តាលមកពីហេតុការណ៍ទាំងអស់ ពិការភាពដោយផ្នែកដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ សម្រាកនៅមន្ទីរពេទ្យបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ជម្ងឺឆ្លងដែលបានកំណត់ (លើកលែងតែហេតុការណ៍ទាំងឡាយណាដែលមានចែងនៅក្នុងករណីមិនធានា) និងជាមួយនិងអត្ថប្រយោជន៍ដល់ថ្ងៃផុតកាលកំណត់ផងដែរ។

**កំណត់សម្គាល់៖ (ត)**

II. ករណីដែលមិនធានា ក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍បណ្តាលពីគ្រោះថ្នាក់ចៃន្យ

បន្ថែមលើប្រការខាងលើ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍មរណភាព ឬ ពិការភាពទាំងស្រុង និង អចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យស្របតាមបណ្ណសន្យារ៉ាប់រងនេះឡើយ ប្រសិនបើមរណភាព ឬពិការភាព ទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងកើតឡើងដោយសារគ្រោះថ្នាក់ចៃដន្យណាមួយ ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្តី ក្នុងចំណោមហេតុការណ៍ដូចខាងក្រោម៖

ក. រាល់ការខាំ ចឹក ឬ ទិច ដោយសត្វគ្រប់ប្រភេទ រួមទាំង សត្វល្អិត មូសខាំ និង ដង្កូវ ឬ សត្វល្អិតរាតត្បាតក្នុងរាងកាយ។ លក្ខខណ្ឌនេះមិនអនុវត្តទេ ចំពោះអត្ថប្រយោជន៍ជម្ងឺឆ្លងដែលត្រូវបានផ្តល់ជូននៅក្នុងផលិតផលនេះ ឬ

ខ. ការព្យាបាលជំងឺខាងវេជ្ជសាស្រ្តណាមួយដែលមិនចាំបាច់។

III. ករណីដែលមិនធានាសម្រាប់ជំងឺឆ្លង

ក. ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍ការពារទៅលើជម្ងឺឆ្លងដូចជា ជម្ងឺកញ្ច្រឹល ជម្ងឺគ្រុនឈាម ជម្ងឺគ្រុនចាញ់ និងជម្ងឺគ្រុនពោះវៀននោះទេ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងត្រូវបានវិនិច្ឆ័យមុន ឬកំឡុងពេល ១៤ (ដប់បួន) ថ្ងៃ រាប់ចាប់ពីថ្ងៃចាប់ផ្តើមកាលបរិច្ឆេទនៃបណ្ណសន្យារ៉ាប់រង។

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង*
*ទៅកាន់បុគ្គលិកលក់/ភ្នាក់ងារធានារ៉ាប់រង*



## អំពីក្រុមហ៊ុន

**ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនស្ហួរិនស៍ (ខេមបូឌា) ម.ក** ដែលជាក្រុមហ៊ុន**បុត្រសម្ព័ន្ធរបស់ ដាយ អ៊ិឈិ ឡាយហ្វ៍ ហូលឌីង** គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយរបស់ប្រទេសជប៉ុនជាមួយ**ប្រតិបត្តិការជាង១២៣ឆ្នាំ** នៅលើសាកលលោក។ **ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ហូលឌីង** មានទីស្នាក់ការកណ្តាលនៅ**ទីក្រុងតូក្យូ ប្រទេសជប៉ុន** និងកំពុង**មានប្រតិបត្តិការអាជីវកម្មនៅ៩ប្រទេស** រួមមាន ប្រទេសជប៉ុន សហរដ្ឋអាមេរិក វៀតណាម ឥណ្ឌា អូស្រ្តាលី ឥណ្ឌូនេស៊ី កម្ពុជា មីយ៉ាន់ម៉ា និងនូវែលសេឡង់។ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ហូលឌីង មានគ្រឹះមូលធនដ៏រឹងមាំជាមួយទ្រព្យសម្បត្តិសរុបចំនួន **៤៦៤.៣ ពាន់លានដុល្លារ** និងបុព្វលាភធានារ៉ាប់រងជាង **៤៥.៣ ពាន់លានដុល្លារ** (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥)។

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅកម្ពុជាក្នុងឆ្នាំ២០១៩ និងមានទីស្នាក់ការកណ្តាលស្ថិតនៅរាជធានីភ្នំពេញ និងការិយាល័យសាខានៅខេត្តបាត់ដំបង និងខេត្តសៀមរាប។ ក្រុមហ៊ុនទទួលបានពានរង្វាន់ជា **«ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិល្អបំផុតប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជា»** រយៈពេល២ឆ្នាំជាប់គ្នាគឺឆ្នាំ២០២៣ និង ២០២៤។ ថ្មីៗនេះយើងក៏ទទួលបានពានរង្វាន់២បន្ថែមទៀតពី **HR Asia** ក្នុងនាមជា **«ស្ថាប័នការងារល្អបំផុតនៅអាស៊ី»** និង **«ពានរង្វាន់ក្រុមហ៊ុនដែលគិតគូរពីបុគ្គលិកបំផុត»** ប្រចាំឆ្នាំ២០២៤។

គិតត្រឹមខែមករា ឆ្នាំ២០២៥ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ កំពុងផ្តល់ការការពារផ្នែកហិរញ្ញវត្ថុជូនប្រជាជនកម្ពុជាចំនួន **១ម៉ឺន៣ពាន់គ្រួសារ** ជាមួយទំហំទឹកប្រាក់ការពារចំនួន **៩១លានដុល្លារអាមេរិក**។ កន្លងមក ក្រុមហ៊ុនបានទូទាត់សំណង និងអត្ថប្រយោជន៍ផ្សេងៗជូនដល់អតិថិជនចំនួនជាង **១ពាន់២រយគ្រួសារ** ក្នុងទំហំទឹកប្រាក់ជាង**៥៩ម៉ឺនដុល្លារអាមេរិក**។


**សម្រាប់ព័ត៌មានបន្ថែម**
**1800 201 202**

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនស្ហួរិនស៍ (ខេមបូឌា) ម.ក
ជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២ អគារសាមគ្គី ផ្លូវលេខ៣១៥ ភូមិ៦
សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

www.dai-ichilife.com.kh | Dai-ichi Life Cambodia | Dai-ichi Life Cambodia Official

## លោកអ្នកអាចជ្រើសរើសជម្រើសនៃការការពារ ដូចខាងក្រោម៖

| តារាងអត្ថប្រយោជន៍ | | គម្រោង SECURE Care | គម្រោង SECURE Care Plus (១) |
|---|---|---|---|
| ១ | អត្ថប្រយោជន៍មរណភាព ឬ ពិការភាពទាំងស្រុង និង អចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រប់ករណី | ១០០% នៃទឹកប្រាក់ត្រូវបានធានា ឬ បុព្វលាភធានារ៉ាប់រងដែលបានបង់សរុប (មួយណាដែលមានចំនួនច្រើនជាង) | ១០០% នៃទឹកប្រាក់ត្រូវបានធានារបស់គម្រោង SECURECare ឬ បុព្វលាភធានារ៉ាប់រងដែលបានបង់សរុប(មួយណាដែលមានចំនួនច្រើនជាង) |
| ២ | អត្ថប្រយោជន៍បន្ថែមសម្រាប់មរណភាព ឬ ពិការភាពទាំងស្រុង និង អចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ | ២០០% នៃទឹកប្រាក់ត្រូវបានធានា | ៦០០% នៃទឹកប្រាក់ត្រូវបានធានា |
| ៣ | អត្ថប្រយោជន៍ទូទាត់ជាមុន សម្រាប់ពិការភាពដោយផ្នែកដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ | រហូតដល់ ២០០% នៃទឹកប្រាក់ត្រូវបានធានា | រហូតដល់ ៦០០% នៃទឹកប្រាក់ត្រូវបានធានា |
| ៤ | អត្ថប្រយោជន៍ដល់ថ្ងៃផុតកំណត (មិនមានការទាមទារសំណង សម្រាប់អត្ថប្រយោជន៍ ល.រទី ១ ដល់ ល.រទី ៣) | ៨៥% នៃបុព្វលាភធានារ៉ាប់រងដែលបានបង់សរុប | ៨៥% នៃបុព្វលាភធានារ៉ាប់រងដែលបានបង់សរុប |
| ៥ | អត្ថប្រយោជន៍ប្រចាំថ្ងៃសម្រាប់ការសម្រាកនៅមន្ទីរពេទ្យបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ | ០.២% នៃទឹកប្រាក់ត្រូវបានធានារហូតដល់ទឹកប្រាក់ចំនួន $ ១៥០ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ | ០.២% នៃទឹកប្រាក់ត្រូវបានធានារបស់ គម្រោង SECURECare រហូតដល់ទឹកប្រាក់ចំនួន $១៥០ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ |
| ៦ | អត្ថប្រយោជន៍ការពារជំងឺឆ្លង | ទឹកប្រាក់ចំនួន ២% នៃទឹកប្រាក់ត្រូវបានធានា រហូតដល់ទឹកប្រាក់ចំនួន $៥០០ (ប្រាំរយ) ដុល្លារអាមេរិក | ទឹកប្រាក់ចំនួន ២% នៃទឹកប្រាក់ត្រូវបានធានារបស់ គម្រោង SECURECare រហូតដល់ទឹកប្រាក់ចំនួន $៥០០ (ប្រាំរយ) ដុល្លារអាមេរិក |
| ៧ | អត្ថប្រយោជន៍រំលែកទុក្ខ | ៥% នៃទឹកប្រាក់ត្រូវបានធានា រហូតដល់ទឹកប្រាក់ចំនួន $២០០០ ដុល្លារអាមេរិក | ៥% នៃទឹកប្រាក់ត្រូវបានធានារបស់គម្រោង SECURECare រហូតដល់ទឹកប្រាក់ចំនួន $២០០០ ដុល្លារអាមេរិក |

**សម្គាល់៖** (១) គម្រោង SECURECare Plus គឺជាគម្រោងធានារ៉ាប់រងបញ្ចូលរវាងគម្រោងមូលដ្ឋាន SECURECare និងគម្រោងបន្ថែម SECURECare Plus ដើម្បីបង្កើនការការពារចំពោះគ្រោះថ្នាក់បន្ថែមទៀត។ (២) & (៣) អត្ថប្រយោជន៍ ២០០% មកពីគម្រោងមូលដ្ឋាន SECURECare និង ៤០០% មកពីគម្រោងបន្ថែម SECURECare Plus

**លោកអ្នកអាចធ្វើការបង់បុព្វលាភតាមវិធីសាស្ត្រដូចជា៖** ប្រចាំខែ ឬ ប្រចាំត្រីមាស ឬ ប្រចាំឆមាស ឬ ប្រចាំឆ្នាំ។

**លោកអ្នកអាចធ្វើការបង់បុព្វលាភតាមវិធីសាស្ត្រដូចជា៖** មូលប្បទានបត្រ ឬ ការផ្ទេរប្រាក់ចូលគណនីធនាគាររបស់ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនសួរ៉ិនស៍ (ខេមបូឌា) ម.ក ឬ បញ្ជាបង់ប្រាក់អចិន្ត្រៃយ៍ ឬ ផ្សេងៗ។

**ចំណាំ៖**

- ប្រសិនបើបុព្វលាភធានារ៉ាប់រងមិនត្រូវបានបង់នៅកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភរ៉ាប់រង នោះ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ នឹងផ្តល់រយៈពេលអនុគ្រោះបន្ថែមចំនួន៣០ថ្ងៃ ជូនដល់អតិថិជនក្នុងការបង់នូវបុព្វលាភធានារ៉ាប់រងចុងក្រោយនោះ។
- ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពឡើងវិញជូនក្រុមហ៊ុន ដាយ អ៊ិ ឈិ ឡាយហ្វ៍ នៅក្នុងរយៈពេលយ៉ាងយូរបំផុត ២ (ពីរ) ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ចុងក្រោយ ដោយលើកលែងការស្នើសុំបន្តសុពលភាពឡើងវិញនៅក្នុងរយៈពេលអនុគ្រោះបន្ថែមចំនួន៣០ថ្ងៃ ដោយគ្រាន់តែបង់បុព្វលាភឡើងវិញតែប៉ុណ្ណោះ។

**ដើម្បីភាពស្ងប់ចិត្ត** លោកសំណាងក៏បានសម្រេចចិត្តទិញកញ្ចប់ធានារ៉ាប់រង SECURECare Plus ជាមួយទឹកប្រាក់ត្រូវបានធានា ១០០០០ ដុល្លារអាមេរិក ដែលផ្តល់នូវការការពារហិរញ្ញវត្ថុ និងភាពស្ងប់ចិត្តសម្រាប់ក្រុមគ្រួសាររបស់គាត់

ឧទាហរណ៍៖




## អត្ថប្រយោជន៍ ដែលលោកសំណាង និងក្រុមគ្រួសារទទួលបាន៖

| ករណីទី១ ក្នុងករណីមានគ្រោះអកុសលកើតឡើង | ប្រសិនបើលោកសំណាងជ្រើសរើស SECURECare | ប្រសិនបើលោកសំណាងជ្រើសរើស SECURECare Plus (១) |
|---|---|---|
| ឆ្នាំទី១ នៃបណ្ណសន្យារ៉ាប់រង លោកសំណាង ក្នុងកំឡុងពេលគាត់ទៅលេងស្រុក លោកសំណាង បានកើតជំងឺគ្រុនឈាម ដែលតម្រូវអោយចូលសម្រាកពេទ្យ | **អត្ថប្រយោជន៍៖** លោកសំណាងទទួលបានទឹកប្រាក់ ២០០ ដុល្លារអាមេរិក ដើម្បីសម្រាលបន្ទុកក្នុងកំឡុងពេលសម្រាកនៅមន្ទីរពេទ្យ | **អត្ថប្រយោជន៍៖** លោកសំណាងទទួលបានទឹកប្រាក់ ២០០ ដុល្លារអាមេរិក ដើម្បីសម្រាលបន្ទុកក្នុងកំឡុងពេលសម្រាកនៅមន្ទីរពេទ្យ |
| ឆ្នាំទី៣ នៃបណ្ណសន្យារ៉ាប់រង លោកសំណាង ជួបគ្រោះថ្នាក់ចៃដន្យពេលធ្វើដំណើរទៅធ្វើការគាត់ បាត់បង់ដៃម្ខាង (ពិការភាពដោយផ្នែក) | **អត្ថប្រយោជន៍៖** លោកទទួលបានទឹកប្រាក់ ១០០០០ ដុល្លារអាមេរិក ដើម្បីសម្រាលបន្ទុកដែលបណ្តាលពីការបាត់បង់នេះក្នុងកំឡុងពេលដែលគ្រួសារគាត់កំពុងជួបការលំបាក | **អត្ថប្រយោជន៍៖** លោកទទួលបានទឹកប្រាក់ ៣០០០០ ដុល្លារអាមេរិក ដើម្បីសម្រាលបន្ទុកដែលបណ្តាលពីការបាត់បង់នេះក្នុង កំឡុងពេលដែលគ្រួសារគាត់កំពុងជួបការលំបាក |
| *ឆ្នាំទី៥នៃបណ្ណសន្យារ៉ាប់រងទទួលមរណភាពដោយគ្រោះថ្នាក់ចៃដន្យពេលធ្វើដំណើរ | **អត្ថប្រយោជន៍៖** គ្រួសារលោកសំណាង ទទួលបានទឹកប្រាក់សំណងលើអត្ថប្រយោជន៍មរណភាពដោយគ្រោះថ្នាក់ចៃដន្យចំនួន ២០០០០ ដុល្លារអាមេរិក និង ៥០០ ដុល្លារអាមេរិក សម្រាប់អត្ថប្រយោជន៍រំលែកទុក្ខ | **អត្ថប្រយោជន៍៖** គ្រួសារលោកសំណាង ទទួលបានទឹកប្រាក់សំណងលើអត្ថប្រយោជន៍មរណភាពដោយគ្រោះថ្នាក់ចៃដន្យចំនួន ៤០០០០ ដុល្លារអាមេរិក និង ៥០០ ដុល្លារអាមេរិក សម្រាប់អត្ថប្រយោជន៍រំលែកទុក្ខ |

ជាមួយនឹងទឹកប្រាក់ដែលទទួលបាន ក្រុមគ្រួសាររបស់លោកសំណាងអាចប្រើប្រាស់សម្រាប់ចំណាយផ្សេងៗ ដូចជាការទូទាត់បំណុល ការផ្គត់ផ្គង់ការសិក្សារបស់កូនៗ ឬ ការចំនាយប្រចាំថ្ងៃ ដោយធានាបានថាជីវភាពរស់នៅរបស់ក្រុមគ្រួសារលោកអាចបន្តជាធម្មតា បើទោះបីជាមិនមានវត្តមានរបស់លោកក៏ដោយ។

| ករណីទី១ ក្នុងករណីមានគ្រោះអកុសលកើតឡើង | ប្រសិនបើលោកសំណាងជ្រើសរើស SECURECare | ប្រសិនបើលោកសំណាងជ្រើសរើស SECURECare Plus (១) |
|---|---|---|
| លោកសំណាងនឹងទទួលបានអត្ថប្រយោជន៍រស់រានមានជីវិតចំនួន៖ | អត្ថប្រយោជន៍៖ លោកសំណាងទទួលបានទឹកប្រាក់ ៨៥% នៃបុព្វលាភធានារ៉ាប់រងដែលបានបង់សរុបសម្រាប់គម្រោង SECURECare | អត្ថប្រយោជន៍៖ លោកសំណាងទទួលបានទឹកប្រាក់ ៨៥% នៃបុព្វលាភធានារ៉ាប់រងដែលបានបង់សរុបសម្រាប់គម្រោង SECURECare Plus |

**កំណត់សម្គាល់៖**
សម្រាប់ពត៌មានលម្អិតនៃផលិតផល សូមយោងទៅកាន់ ខ និង លក្ខខណ្ឌនៃផលិតផលនេះ៖

**ករណីមិនធានាចំបង**

I. ករណីដែលមិនធានា ក្នុងករណីទទួលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍

ក. ធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទការចាប់ផ្តើមមានសុពលភាពនៃការបន្តសុពលភាពឡើងវិញ ដោយមិនគិតអំពីស្ថានភាពផ្លូវចិត្តរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលយកកាលបរិច្ឆេទចុងក្រោយគេ ឬ

ខ. ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ការប៉ុនប៉ងធ្វើអត្តឃាត ការប៉ុនប៉ងធ្វើបាបខ្លួនឯង ឬបង្ករបួសលើខ្លួនឯងដោយចេតនា ទោះបីស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

គ. ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍ ឬ

ឃ. ការប្រើប្រាស់គ្រឿងញៀន ឬសារធាតុញៀនខុសច្បាប់ផ្សេងទៀត ឬ

ង. បទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អ្នកទទួលផល ឬ

ច. ពិការភាពជំងឺឬរបួសដែលកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទបន្តសុពលភាពឡើងវិញ

ឆ. សង្គ្រាម (ប្រកាស ឬមិនបានប្រកាស) ភាពចលាចល ឬ ប្រតិបត្តិការសង្គ្រាម សង្គ្រាមស៊ីវិល ការបះបោរ ឬ ភាពវឹកវរក្នុង ប្រទេស ឬ កុប្បកម្ម ឬ កូដកម្ម ឬ

ជ. គ្រឿងផ្ទុះ ឬវិទ្យុសកម្មដោយសារតែអាវុធអាតូមិច នុយក្លេអ៊ែរ ឬអាវុធគីមី ឧបករណ៍ ឬគ្រឿងផ្ទុះកៃច្នៃ ឬ

ឈ. មរណភាព ឬការរងរបួសដែលកើតឡើងខណៈពេល ឬដោយសារតែអ្នកត្រូវបានធានារ៉ាប់រងសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងដែលលើសពីដែនកំណត់ដោយច្បាប់ និងបញ្ញត្តិជាធរមាន ឬ ដែលនាំឱ្យមានការបំពានលើដែនកំណត់ល្បឿនដែលកំណត់ដោយច្បាប់ចរាចរណ៍ជាធរមាននៅពេលមានគ្រោះថ្នាក់ ឬ

ញ. ការជិះជាមួយ ឬបើកបរក្នុងការប្រណាំងកីឡាវិជ្ជាជីវៈណាមួយ ឬសកម្មភាពជ្រមុជទឹកពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ដកដង្ហើម ឬ

ដ. សកម្មភាពហោះហើរ ឬអាកាសចរណ៍នានា លើកលែងតែការធ្វើដំណើរបង់ប្រាក់តាមយន្តហោះដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ មានលក្ខណៈពាណិជ្ជកម្ម និងមានកាលវិភាគនៃការធ្វើដំណើរ។